# ទស្សនៈក្រុមអ្នករៀបរៀង ចងក្រង និងបោះពុម្ព

## អកនិដ្ឋព្រហ្ម ព្រះព្រហ្មរក្សាលោក

## អរិយបុគ្គលអ្នកបំភ្លឺធម៌ព្រះពុទ្ធពាក់កណ្ដាល៥០០០ព្រះវស្សា

**អកនិដ្ឋព្រហ្ម ព្រះព្រហ្មរក្សាលោក** គឺជាចំណងជើងថ្មីមួយ ដែលក្រុមការងារអ្នករៀបរៀង ចងក្រង និងបោះពុម្ព សម្រេចប្ដូរពីចំណងជើងចាស់ **កតញ្ញូជន ធម៌កតញ្ញូ ពន្លឺបំភ្លឺលោក** ដើម្បីឱ្យត្រូវត្រឹមចំបេសកកម្មរបស់ព្រហ្មរក្សាលោកព្រះនាម **អកនិដ្ឋព្រហ្ម ជាព្រហ្មសម្មាទិដ្ឋិ** បានសម្រេចធម៌ជាន់ខ្ពស់ថ្នាក់អនាគាមី ជារូបព្រហ្មខ្ពស់ជាងគេបំផុតនៅឋានសុទ្ធាវាស មានអាយុ១៦០០០មហាកប្ប ឬ៦៤០០០កប្ប ដែលបេសកកម្មរបស់លោក តែងតែចុះមកយកសម្បកជាមនុស្សដើម្បីបំភ្លឺធម៌នាពាក់កណ្ដាលកម្ចាំងត្រាស់ដឹងរបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ ហើយក្នុងកប្បណា ឬផែនដីណាដែលពុំមានព្រះពុទ្ធត្រាស់ដឹងទេ **អកនិដ្ឋព្រហ្ម** តែងចុះមកយកសម្បកជាមនុស្ស **ធ្វើជាស្ដេចចក្រ** គ្រប់គ្រងពិភពលោក ហើយអប់រំមនុស្សឱ្យមានសីលធម៌ ដឹងខុសដឹងត្រូវ រស់នៅបានជាទីពឹងដល់មនុស្សផងគ្នា។ **អកនិដ្ឋព្រហ្ម ព្រះព្រហ្មរក្សាលោក** គឺជាកម្រងសំណេរមេរៀនស្រង់ចេញពីគណនីហ្វេសប៊ុក **លោកពូវាសនា**។ កម្រងសំណេរមេរៀននេះ គឺជាការសរសេរស្រាយបំភ្លឺនូវព្រះធម៌ដើមដែលបានត្រាស់សម្ដែងដោយ **ព្រះសម្មាសម្ពុទ្ធព្រះនាមសមណគោតមព្រះបរមគ្រូនៃយើង** ដែលជាបុគ្គលបានសម្រេចការត្រាស់ដឹងកាលពីជាង២៥០០ព្រះវស្សាមុន ឱ្យត្រឹមត្រូវតាមន័យដើម ដូចការប្រមើលទុករបស់ព្រះអង្គមកថា **នៅពាក់កណ្ដាល២៥០០ព្រះវស្សានៃកម្ចាំងត្រាស់ដឹងរបស់ព្រះអង្គ ព្រះធម៌នឹងត្រូវបានបំភ្លឺម្ដងទៀត គឺមានអ្នកយល់ពីធម៌ដែលព្រះពុទ្ធសម្ដែង នឹងចេញមកបំភ្លឺធម៌ ឬសម្ដែងប្រាប់ពីសភាពពិតដែលធម្មជាតិនេះប្រព្រឹត្តទៅ ពីលក្ខណៈកកើតលោក និងការកកើតជីវិតសត្វលោកជាថ្មីម្ដងទៀតមុននឹងធម៌ត្រូវរលត់**

*ន័យក្នុងរយៈពេល៥០០០ព្រះវស្សា ក្រោយព្រះពុទ្ធបរិនិពាន។*

*ដោយហេតុមានជំនឿបែបនេះហើយ បានក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្មែរយើង យើងធ្លាប់បានឮរួចមកហើយថា ពាក់កណ្ដាលសាសនា ព្រះធម៌នឹងភ្លឺម្ដងទៀត។ បើគិតមកដល់ពេលនេះ គឺចូលពុទ្ធសករាជ២៥៦២ព្រះវស្សា លើស៦២ឆ្នាំហើយ តែប្រជាពលរដ្ឋខ្មែរ ក៏ដូចប្រទេសនានានៅលើសកលលោកដែលកាន់ព្រះពុទ្ធសាសនា នៅតែមិនទាន់ឃើញមានព្រឹត្តិការណ៍អស្ចារ្យ ឬវត្តមានអ្នកមានបុណ្យនៅឡើយទេ។ តើពាក់កណ្ដាលសាសនាបានឈានចូលមកដល់ហើយឬនៅ? បើមិនទាន់ឈានចូលមកដល់ទេ តើពេលណា? បើពាក់ កណ្ដាលសាសនា បានឈានចូលមកដល់ហើយ ចុះហេតុដូចម្ដេច ក៏មិនទាន់ឃើញអ្នកមានបុណ្យចេញមកលើកសាសនា? តើនៅសល់ប៉ុន្មានឆ្នាំទៀត? ឬប៉ុន្មានទសវត្សរ៍ទៀត ទើបបានតួអង្គអ្នកមានបុណ្យចេញមកលើកសាសនា? នេះជាចម្ងល់ដែលព្រះសង្ឃ តាអាចារ្យលោកយាយលោកតា ពុទ្ធបរិស័ទ អ៊ំពូមីង បងប្អូនស្រីប្រុសដែលគោរពប្រតិបត្តិព្រះពុទ្ធសាសនា តែងតែឆ្ងល់ និងទន្ទឹងរង់ចាំអ្នកមានបុណ្យមកជួយស្រុកខ្មែរ។*

*បើយោងតាមគេហទំព័រ* https://puthtomneayblog.wordpress.com *ប្រទេសខ្មែរយើង ក៏ដូចជាប្រទេសនានាដែលប្រកាន់ជំនឿលើព្រះពុទ្ធសាសនាបាននាំគ្នា ប្រារព្ធពិធីបុណ្យធំពាក់កណ្ដាលសាសនា យ៉ាងមហោឡារិកក្នុងរយៈពេលប្រាំពីរថ្ងៃប្រាំពីរយប់។ ដោយឡែក នៅប្រទេសកម្ពុជាវិញ យើងមានទាំងប្រារព្ធពិធីបុណ្យដង្ហែរព្រះសារីរិកធាតុ ពីប្រទេសស្រីលង្កា មកតម្កល់ទុកនៅព្រះសក្យមុនីចេតិយនៅមុខស្ថានីយអយស្ម័យយាននៅទីក្រុងភ្នំពេញយ៉ាងអធិកអធមក្រៃលែងថែមទៀតផង។ ការដង្ហែរព្រះសារីរិកធាតុជាលើកទី១ នៅពាក់កណ្ដាលសាសនា គឺចំពុទ្ធសករាជ២៥០០ព្រះវស្សា គឺត្រូវជាឆ្នាំ១៩៥៧ នៃគ្រឹស្តសករាជ តែនៅតែមិនឃើញមានសញ្ញាអ្នកមានបុណ្យ ចេញ*

មកបំភ្លឺធម៌នាពាក់កណ្ដាល៥០០០ព្រះវស្សាទេនាពេលនោះ។ អស់កាល៤៥ឆ្នាំក្រោយមក គឺស្មើនឹងរយៈពេលដែលព្រះពុទ្ធទ្រង់បានចេញប្រោសសត្វលោកអស់កំណត់កាល៤៥ឆ្នាំដែរ គឺនៅពុទ្ធសករាជ២៥៤៥ ត្រូវនឹងឆ្នាំ២០០២ មានការដង្ហែរព្រះសារីរិកធាតុជាលើកទី២ ចេញពីព្រះសក្យមុនីចេតិយចាស់ដង្ហែរទៅតម្កល់ទុកនៅព្រះសក្យមុនីចេតិយថ្មីនៅភ្នំព្រះរាជទ្រព្យ (ភ្នំឧដុង្គ)។ បើយោងតាមគេហទំព័រពុទ្ធទំនាយខាងលើដដែល បានសរសេរកាលពីឆ្នាំ២០១៣ថា នៅសល់រយៈពេល៦ឆ្នាំទៀត ទើបព្រះបាទធម្មិកចេញបំភ្លឺធម៌គឺនៅចំ**ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ២៥៦៣ ត្រូវនឹងឆ្នាំ២០១៩**។ តើមានអ្វីកើតឡើងក្នុងឆ្នាំ២០១៩កន្លងមក? បើយោងតាមការអះអាងខាងលើ យើងសង្កេតឃើញថា នៅក្នុងកម្មវិធីគម្រប់ខួប៥៤ឆ្នាំរបស់**លោកពូវាសនា នាថ្ងៃពុធ ១៥ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ២៥៦៣ ជាថ្ងៃសីល ពេញបូណ៌មី ត្រូវនឹងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩** នៅលើគណនីសង្គមផ្ទាល់ខ្លួនរបស់លោកពូ លោកពូបានផ្ដល់នូវកាដូសម្រាប់សមាជិកគ្រួសារសម្ព័ន្ធ និងអ្នកដែលមានឧបនិស្ស័យ **អំពីរបៀបដែលសព្វសត្វ និងចក្រវាលរបស់សត្វកើត** ហៅថា **"ធម្មចក្កប្បវត្តនសូត្រ"** ដែលព្រះសម្មាសម្ពុទ្ធបានត្រាស់ សម្ដែងដំបូងគេប្រោសបញ្ចវគ្គីភិក្ខុ ក្រោយព្រះអង្គសោយវិមុត្តិសុខអស់កាល៤៩ថ្ងៃក្រោយការត្រាស់ដឹង។ លោកពូបានសរសេរពន្យល់ថា **ចក្រវាលរបស់អ្នក កើតមកពីអ្វី? កើតមកពីកម្លាំងវិលនៃកលាបៈ ឬហៅថាកម្ម ត្រង់នេះ ទើបព្រះពុទ្ធសម្ដែងថា "នត្ថិ កម្មំ សមំ ពលំ" គ្មានកម្លាំងណាស្មើកម្ម នេះទេ គឺគ្មានកម្លាំងអ្វីស្មើកម្លាំងកលាបៈវិលនេះទេ។ ចក្រវាលរបស់អ្នក រួមទាំងអ្នកផង កើតឡើងពីកម្លាំងកលាបៈវិលហ្នឹង (គឺកើតពីកម្ម កម្មន្ត force) អ្នកស្រមៃមើល បើអ្នកចាប់កលាបៈឱ្យឈប់វិល ចក្រវាលអ្នក និងអ្នក នឹងបាត់ទាំងអស់ តើចក្រវាលនេះ កើតពីអ្វី? គឺកើតពីកម្ម ពីកម្លាំង មិនមែនពីធាតុទេ។** តើការណ៍នេះ

ស៊ីសង្វាក់គ្នានឹងការអះអាងក្នុងគេហទំព័រពុទ្ធទំនាយខាងលើដែរឬទេថា នៅចុងឆ្នាំ២០១៩ ព្រះបាទធម្មិក នឹងចាប់ផ្តើមចេញបំភ្លឺធម៌ព្រះសម្មាសម្ពុទ្ធសាជាថ្មី? តើក្នុងសម័យនេះ មានអ្នកណាដឹងថាពិភព លោកនេះកើតពីកម្លាំងនៃកលាបៈដែលមានធាតុដីទឹកភ្លើងខ្យល់វិលទេ? តើនេះមិនមែនជា ព្រឹត្តិការណ៍ដ៏អស្ចារ្យដែលគួរឱ្យយើងភ្ញាក់ទេ?

ក្នុងសម័យកាលមានព្រះសម្មាសម្ពុទ្ធត្រាស់ដឹង សត្វមានឱកាសបានស្តាប់ការពន្យល់ធម៌ដោយផ្ទាល់ពីព្រះអង្គ ហើយសត្វក៏មានឱកាសដ៏ច្រើនដើម្បីសម្រេចបានធម៌ជាន់ខ្ពស់តិចបំផុតអរិយបុគ្គលថ្នាក់សោតា និងខ្ពស់បំផុតថ្នាក់ព្រះអរហន្ត ព្រោះព្រះសម្មាសម្ពុទ្ធព្រះអង្គជាព្រះអរហន្ត។ ឱកាសដ៏ក្រៃក្រនេះបានកន្លងផុតទៅជាង២៥០០ព្រះវស្សាហើយ ផុតបាត់ហើយ! ហើយខ្មែរយើង បាននិងកំពុងទន្ទឹងរង់ចាំផ្លូវអ្នកមានបុណ្យមកជួយក៏ជាង២៥០០ព្រះវស្សាដែរ។ ចំណែកក្នុងសម័យកាលព្រហ្មរក្សាលោកឈ្មោះ **អកនិដ្ឋព្រហ្ម** ចុះមកបំភ្លឺធម៌ សត្វក៏មានឱកាសស្តាប់ការពន្យល់ធម៌នេះសាជាថ្មីដោយផ្ទាល់ពីលោកដែរ ហើយសត្វក៏មានឱកាសដ៏ច្រើនដើម្បីសម្រេចបានធម៌ជាន់ខ្ពស់តិចបំផុតថ្នាក់សោតា ហើយខ្ពស់បំផុតថ្នាក់អនាគាមី ព្រោះព្រហ្មរក្សាជាព្រហ្មអនាគាមី។ ព្រះពុទ្ធសម្តែងថា **“យោធម្មំ បស្សតិ សោមំ បស្សតិ” ឃើញធម៌ គឺឃើញតថាគត** ដូចគ្នានេះដែរ ទាល់តែទ្វារមនោយើងបានយល់ធម៌ដែលជាដំណើរធម្មជាតិ ដែល **អកនិដ្ឋព្រហ្ម** បាននិងកំពុងបំភ្លឺ ឱ្យត្រឹមត្រូវតាមន័យដើមនៃការបង្រៀនរបស់ព្រះពុទ្ធអង្គ ទើបយើងអាចស្គាល់ព្រហ្មរក្សាលោកចុះមកបំភ្លឺធម៌នាពាក់កណ្តាល៥០០០ព្រះវស្សា។ លោកអ្នកដែលយល់ពីដំណើរធម៌ តែងស្រែកឧទានដោយអំណរថា ឱ!ម្ចាស់ថ្លៃអើយ! រឿងដែលខ្ញុំឈឺចាប់យូរហើយ រឿងដែលខ្ញុំមិនដឹងយូរហើយ ឥឡូវខ្ញុំបានដឹងដោយព្រះអង្គពន្យល់ប្រាប់ មិនមែនព្រះអង្គឱ្យខ្ញុំជឿទេ គឺឱ្យខ្ញុំព្រះករុណាប្រើខួរក្បាលគិត

*ហើយយល់បានទេតើ អស្ចារ្យណាស់ព្រះអង្គអើយ! ខ្ញុំរកអ្វីមកថ្លៃង឵ឱ្យសមនឹងចិត្តអរគុណចំពោះគុណរបស់ព្រះអង្គមិនបានទេ ព្រះអង្គជាអ្នកបើកផ្សារនូវរបស់ដែលផ្កាប់តាំងពីយូរយារណាស់មកហើយ ហើយការយល់ធម៌នេះ វាមានប្រយោជន៍សម្រាប់ខ្ញុំព្រះករុណាលើសរបស់អ្វីទាំងអស់ក្នុងលោកដែលខ្ញុំរកបាន។*

*រឿងនឹកស្មានមិនដល់សោះនឹងកើតមានពិត ក្នុងអំណាចកម្លាំងត្រាស់ដឹងរបស់ព្រះពុទ្ធព្រះនាមសមណគោតម។ ឥឡូវជាពេលវេលាសមស្របដល់សព្វសត្វហើយ សូមលោកអ្នកទាំងឡាយ បើកសោតប្រសាទដើម្បីស្ដាប់ឱ្យយល់នូវធម៌ដែលព្រះពុទ្ធសម្ដែង ដើម្បីបានជាប្រទីបនាំផ្លូវក្នុងដំណើរជីវិតនៃវាលវដ្តសង្សារ និងបានទៅជួបកតញ្ញូជនកំពូលនៅក្នុងអនាគតជាតិដ៏យូរលង់ខាងមុខ។ ការបំភ្លឺធម៌ពីពេលនេះទៅដល់ពេលព្រះសិអារ្យមេត្រីត្រាស់គឺមានតែម្ដងនេះទៀតគត់។ សូមសព្វសត្វកុំធ្វេសប្រហែសឱ្យឱកាសដ៏ក្រក្រៃនេះកន្លងផុតទៅឱ្យសោះ។ ព្រឹត្តិការណ៍បំភ្លឺធម៌នាពាក់កណ្ដាល៥០០០ព្រះវស្សា នៃកម្លាំងត្រាសដឹងរបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមសមណគោតមដែលខ្មែរយើង បាននិងកំពុងទន្ទឹងរង់ចាំដ៏យូរស្ទើរតែអស់សង្ឃឹមទៅ ហើយនោះនឹងដល់កាលវេលាយ៉ាងប្រាកដក្នុងពេលដ៏ខ្លី និងសមគួរខាងមុខនេះហើយ។ សូមលោកអ្នកដែលមានសទ្ធាជ្រះថ្លានឹងព្រះពុទ្ធអង្គ ស្ដាប់ធម៌ឱ្យយល់ រួចបដិបត្តិខ្លួនតាមផ្លូវត្រូវក្នុងដំណើរដ៏សុខសាន្តទៅជួបព្រះសិអារ្យមេត្រី។ សូមលោកអ្នករីករាយនឹងជីវិតយល់ធម៌ តាមរយៈសៀវភៅធម៌ដែលក្រុមការងារបាននិងកំពុងប្រមូលចងក្រងបោះពុម្ពផ្សាយជាបន្តបន្ទាប់ទៅនេះ។* ***សព្វទានំ ធម្មទានំ ជិនាតិ គ្មានការឱ្យទានណាប្រសើរថ្លៃថ្លាជាងការពន្យល់មនុស្សឱ្យកើតបញ្ញា គឺការយល់ធម៌ ឬយល់ដំណើរធម្មជាតិនេះទេ*** *ហើយការពន្យល់ដែលជាធម្មទាននេះ មានពន្យល់យ៉ាងពិស្ដារក្នុងសៀវភៅ* ***កតញ្ញូជន ធម៌កតញ្ញូ***

***ពន្ទឺបំភ្លឺលោកភាគ១ ភាគ២ ក៏ដូចក្នុងសៀវភៅ អកនិដ្ឋព្រហ្ម ព្រះព្រហ្មរក្សាលោកភាគ៣ និងភាគបន្តបន្ទាប់ទៀត។*** *សូមឱ្យសព្វសត្វ! បានទទួលនូវការយល់ត្រូវអំពីការបំភ្លឺធម៌សាជាថ្មីដោយ* ***អកនិដ្ឋព្រហ្ម ព្រះព្រហ្មរក្សាលោក*** *នាពាក់កណ្ដាល៥០០០ព្រះវស្សានៃកម្លាំងត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធតាមឧបនិស្ស័យរបស់សព្វសត្វ។ សូមបងប្អូនជនរួមជាតិ រីករាយនឹងដំណើរជីវិតយល់ធម៌របស់បងប្អូនផងចុះ។* ***សព្វរសំ ធម្មរសោ ជិនាតិ*** *គ្មានរសអ្វីប្រសើរថ្លៃថ្លាស្មើនឹងរសព្រះធម៌ឡើយ៕*

*ថ្ងៃពុធ ៩កើត ខែបុស្ស ឆ្នាំជូត ទោស័ក ពុទ្ធសករាជ២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០*
*ក្រុមអ្នករៀបរៀង ចងក្រង និងបោះពុម្ព*

# អារម្ភកថា

***"កតញ្ញូជន ធម៌កតញ្ញូ ពន្លឺបំភ្លឺលោក"*** *ក្រោយការប្រមើលមើលនៃបុគ្គលត្រាស់ដឹង ដែលលោកបានសម្រេចពន្លឺត្រាស់ដឹងកាលពីជាង២៥០០ឆ្នាំមុន ព្រះសាមណគោតមអំពីពន្លឺព្រះធម៌ ដែលនឹងមានពន្លឺភ្លឺម្តងទៀតសម្រាប់សត្វលោក ពេលនេះជាពេលវេលាដ៏សមគួរហើយ ដែលកំពូលកតញ្ញូជននាសម័យនេះ គឺលោកពូរបស់ពួកយើង* ***"លោកពូវាសនា"*** *ជាបុគ្គលដែលបានស្ថិតក្នុងការប្រមើលមើលរបស់ព្រះពុទ្ធគោតម ព្រះបរមគ្រូនៃយើង បានចាប់ផ្តើមបកស្រាយព្រះធម៌ដើមដែលបានត្រាស់សម្តែងដោយព្រះសាមណគោតម ព្រះបរមគ្រូនៃយើងកាលពីជាង២៥០០ឆ្នាំមុននោះ។ នេះជាកិច្ចការនៃការបោសសម្អាតគ្រឿងសៅហ្មងចេញពីមេរៀនដើមដែលជាមេរៀនត្រាស់ដឹងដ៏អស្ចារ្យនៃព្រះពុទ្ធព្រះបរមគ្រូនៃយើង។ អស់រយៈពេលជាង១០ឆ្នាំហើយ ដែលលោកពូរបស់ពួកយើង បានធ្វើការពន្យល់ ធ្វើការតម្រង់ទិដ្ឋិ ពីភាពត្រឹមត្រូវ ពីតម្លៃ ពីសេចក្តីថ្លៃថ្នូរ ពីភាពសមគួរក្នុងការរស់នៅ ឬការរស់នៅជាមនុស្សមានតម្លៃ ជាមនុស្សកតញ្ញូ។ នេះជាកិច្ចការរបស់លោកជា* ***"កតញ្ញូជន"*** *គឺ* ***"ទិដ្ឋុជុកម្ម"*** *។ មកដល់ពេលនេះ តាមរយៈកិច្ចការរបស់លោកក្នុងការតម្រង់ការយល់របស់មនុស្ស អស់រយៈពេលជាង១០ឆ្នាំមកនេះពួកយើងជាកូន ជាប្អូន ជាក្មួយ ពិតជាបានដឹង និងទទួលអត្ថប្រយោជន៍ពីភាពត្រឹមត្រូវភ្លឺស្វាងក្នុងការរស់នៅ រហូតមកដល់ពេលចុងក្រោយនេះ ពួកយើងពិតជាភ្ញាក់ខ្លួនយ៉ាងខ្លាំង ដែលមេរៀនទាំងឡាយដែលលោកពូបានផ្តល់ឱ្យជាង១០ឆ្នាំមកនេះ មិនត្រឹមតម្រង់ការរស់នៅដ៏ត្រឹមត្រូវភ្លឺស្វាងក្នុងជីវិតជាមនុស្សប៉ុណ្ណឹងនោះទេ តែវាថែមទាំងបានក្លាយជាប្រទីបបំភ្លឺផ្លូវដំណើរជីវិតរបស់ពួកយើងក្នុងវាលវដ្តសង្សារដ៏ងងឹតនេះបន្ទាប់ពីជីវិតជាតិនេះទៅ។ ឥឡូវនេះ ពួកយើងដឹងជាក់ច្បាស់ហើយ ពីកិច្ចការរបស់លោកដ៏ពិតប្រាកដ*

លោកជាបុគ្គលខ្ពង់ខ្ពស់ណាស់ **"ជាកំពូលកតញ្ញូជននាសម័យនេះ"** ជាបុគ្គលដែលជាអ្នកមកបោសសម្អាតព្រះធម៌ត្រាស់ដឹងរបស់ព្រះពុទ្ធ ព្រះបរមគ្រូនៃយើង ហើយអ្វីដែលលោកបានផ្ដល់ឱ្យជាមេរៀនដល់ពួកយើងកន្លងមក គឺ **"ការតម្រង់វិញ្ញាណដឹងត្រូវ វិញ្ញាណកតញ្ញូ គឺទិដ្ឋុជុកម្ម"**។

នេះជារឿងអស្ចារ្យណាស់ ជារឿងដ៏សំណាងណាស់ ជារឿងដ៏កម្រណាស់ ដែលកំណើតរបស់ពួកយើង បានមកជួបប្រសព្វនឹងបុគ្គលដ៏អស្ចារ្យ បុគ្គលដែលមានវិញ្ញាណដឹងដ៏ខ្ពង់ខ្ពស់នៃទីឋានព្រហ្ម ដែលជាអ្នកត្រូវមកបោសសម្អាតព្រះធម៌របស់ព្រះពុទ្ធគោតមនៃយើង ដែលបានត្រាស់សម្ដែងកាលពីជាង២៥០០ឆ្នាំមុន។ មកដល់ត្រង់នេះ ក្រៅពីចិត្តដឹងគុណលោកដែលនឹងមិនដឹងរកពាក្យអ្វីឱ្យសមនឹងគុណរបស់លោក ពន្លឺ ភាពភ្លឺស្វាងក្នុងជីវិតពេលបច្ចុប្បន្ន និងអនាគតជាតិ គឺពួកយើងបានដឹងផ្លូវយ៉ាងច្បាស់ថាត្រូវទៅទីណា នេះក៏ព្រោះ **"ពន្លឺធម៌កតញ្ញូ វិញ្ញាណកតញ្ញូ វិញ្ញាណភ្លឺស្វាង វិញ្ញាណដឹងផ្លូវ"** ដែលលោកតម្រែតម្រង់ជាង១០ឆ្នាំមកនេះ គឺ **"កតញ្ញូជនធ្វើទិដ្ឋុជុកម្ម តម្រង់វិញ្ញាណដឹងត្រូវ"**។ ពួកយើងដែលដឹងផ្លូវ ស្គាល់គុណស្គាល់ទោស ជាមនុស្សកតញ្ញូ ដឹងពីសារៈប្រយោជន៍ដ៏មហាសាលនៃពន្លឺកតញ្ញូនេះ ធម៌កតញ្ញូនេះសម្រាប់ពេលបច្ចុប្បន្ននេះផង និងទៅអនាគតជាតិបន្តៗផង ពួកយើងកើតមានចិត្តសង្វេគៗដល់សព្វសត្វលោក ដែលគ្មានរស់នៅក្នុងដំណើរងងឹត គ្មានសូម្បីពន្លឺដ៏តូចមួយក្នុងដៃនៃដំណើរយោលយោគជាតិកំណើតក្នុងវាលវដ្តសង្សារដ៏ងងឹតនេះ។ ដូច្នេះ ជាការចងក្រងនូវសំណេរមេរៀនរបស់លោកពូ ដែលលោកបានសរសេរពន្យល់ពីសច្ចៈធម៌ ដែលជាមេរៀនត្រាស់ដឹងនៃព្រះសាមណគោតម ព្រះបរមគ្រូនៃយើងក្នុងពេលនេះ ពួកយើងយល់ថា វានឹងបានចូលរួមជាការផ្ដល់ពន្លឺមួយផ្នែកដល់មនុស្សដែលមានឧបនិស្ស័យ តាមរយៈអត្ថបទពន្យល់របស់លោកពូទាំងអម្បាលម៉ានពី

សច្ចៈធម៌នេះ។ ជាង២៥០០ឆ្នាំក្រោយព្រះពុទ្ធលោកបរិនិព្វាន ពេលនេះជាពេលវេលាដ៏សមគួរហើយ ដែលមេរៀនត្រាស់ដឹងរបស់ព្រះអង្គនឹងចាប់ផ្ដើមមានពន្លឺដល់សត្វលោកម្ដងទៀត។ ដូច្នេះ តាមរយៈអត្ថបទសំណេរចងក្រងមួយនេះ សូមឱ្យសព្វសត្វបានទទួលពន្លឺព្រះធម៌ បានជាប្រទីបបំភ្លឺផ្លូវជីវិតក្នុងដំណើរដ៏វែងឆ្ងាយទៅតាមឧបនិស្ស័យរៀងៗខ្លួនក្នុងវាលវដ្ដសង្សារនៃអន្ធង់អវិជ្ជាដ៏ងងឹតរកទីបំផុតគ្មាននេះ៕

ថ្ងៃព្រហស្បតិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
ក្រុមអ្នករៀបរៀង ចងក្រង និងបោះពុម្ព